# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងបរិស្ថាន
........................

# សេចក្តីព្រាង
# ច្បាប់
# ស្តីពី
# ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**ថ្ងៃទី................ខែ...................ឆ្នាំ ...............**

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ច្បាប់នេះមានគោលដៅគាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ ធានាឱ្យបាននូវការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ស្របតាមមាត្រា ៣២ និង ៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយការបង្កើតនូវយន្តការផ្លូវច្បាប់នានា ក្នុងការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់រាល់គម្រោងវិនិយោគទាំងអស់ គម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពនានា ដែលបង្កហេតុប៉ះពាល់ និងគ្រោះថ្នាក់ដល់បរិស្ថាន សង្គម សេដ្ឋកិច្ច វប្បធម៌ នីត្យានុកូលភាព និងលទ្ធិប្រជាធិបតេយ្យរបស់រដ្ឋ ។

**មាត្រា ២._**

ច្បាប់នេះមានគោលបំណង៖

១. កំណត់ឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍សាធារណៈ និងឯកជន មុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច

២. លើកកម្ពស់ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន និង

៣. ធានាការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យមានប្រសិទ្ធភាព តម្លាភាព និងសមធម៌សង្គម ។

**មាត្រា ៣._**

- ច្បាប់នេះមានវិសាលភាពអនុវត្តទាំងស្រុង និងយ៉ាងពេញលេញលើគម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានា របស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រតិបត្តិការរួច កំពុងប្រតិបត្តិការ ឬចាប់ផ្តើមប្រតិបត្តិការ ដែលបានប៉ះពាល់ ឬអាចនាំឲ្យកើតមានហេតុប៉ះពាល់ដល់បរិស្ថាន និងសង្គម ។
- ប្រភេទគម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានា ដែលបង្កឱ្យមានផលប៉ះពាល់បរិស្ថានមធ្យមឬធ្ងន់ធ្ងរ និង/ឬ ដែលបានកំណត់ដោយឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានា ដែលទទួលបានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ សេចក្តីសម្រេចពីក្រសួង និងស្ថាប័នអនុម័តគម្រោង ហើយមិនបានសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៤._**

ច្បាប់នេះមិនអនុវត្តចំពោះគម្រោង និងសកម្មភាពរបស់រដ្ឋ ដែលបានសម្រេចដោយរាជរដ្ឋាភិបាល ឬបានអនុម័តពីរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងបន្ទាន់ទាក់ទងនឹងវិស័យសន្តិសុខជាតិ ការពារជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ៥._**

និយមន័យ និងសទ្ទានុក្រម នៃច្បាប់នេះមានចែងក្នុងឧបសម្ព័ន្ធ ។

# ជំពូកទី ២
# គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦._**

រាល់គម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានា ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់ទៅលើ បរិស្ថាន សេដ្ឋកិច្ច សង្គម សុខភាពនិងវប្បធម៌ឲ្យបានត្រឹមត្រូវជាមុនសិន មុនបញ្ជូនទៅរាជរដ្ឋាភិបាលឯកភាព និងអនុម័ត ។ ប្រភេទគម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានាដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

រាល់គម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានា ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យ មិនត្រូវចាប់ផ្តើមការងារសាងសង់ ឬដំណើរការ ដោយគ្មានលិខិតឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានចេញដោយក្រសួងបរិស្ថានឡើយ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យឯកជន សង្គមស៊ីវិល និងអ្នកដែលទទួលរងហេតុប៉ះពាល់មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងអំឡុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៧._**

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

រូបវន្តបុគ្គល នីតិបុគ្គល សង្គមស៊ីវិល និងអ្នកដែលទទួលរងហេតុប៉ះពាល់ពីគម្រោងមានសិទ្ធិទទួលបាននូវព័ត៌មាន និងចូលរួមក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវប្រកាន់យក និងអនុវត្តគោលការណ៍បង្ការ និងទប់ស្កាត់។ ក្នុងករណីមានការគម្រាមកំហែង អំពីការខូចខាតដល់បរិស្ថានធ្ងន់ធ្ងរ ឬមិនអាចជួសជុលបាន កង្វះខាតភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រមិនអាច យកមកធ្វើជាមូលហេតុដើម្បីផ្អាកការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការខូចខាតដល់គុណភាពបរិស្ថាន និងធនធានជីវៈចម្រុះឡើយ។

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវប្រកាន់យក និងអនុវត្តគោលការណ៍អ្នកបង្កការខូចខាតបរិស្ថានត្រូវទូទាត់សំណង។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កឲ្យមានការបំពុលបរិស្ថាន សំណល់ ឬបង្កការខូចខាតដល់បរិស្ថានក្រោមរូបភាពផ្សេងៗទៀត ត្រូវរ៉ាប់រងបង់ថ្លៃចំណាយលើការខូចខាត ការទប់ស្កាត់ ការបញ្ចៀស ឬការកាត់បន្ថយការខូចខាត។

# ជំពូកទី ៣
# អង្គភាពទទួលខុសត្រូវ

**មាត្រា ៨._**

ក្រសួងបរិស្ថានជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចគ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងអស់ ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចេញលិខិតអនុញ្ញាតនានា ពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់ បរិស្ថានបន្ទាប់ពីមានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសមត្ថកិច្ចតាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ចអង្កេត ស្រាវជ្រាវ ណែនាំ និងចាត់វិធានការដោយខ្លួនឯង ឬដោយសហការជាមួយភាគីពាក់ព័ន្ធ ចំពោះគម្រោង និងសកម្មភាពគ្រប់ប្រភេទ ។

ចំពោះរាល់សកម្មភាព និងគម្រោងដែលទទួលបានការឯកភាពជាមុនពីរាជរដ្ឋាភិបាល ឬមានអាជ្ញាប័ណ្ណ សេចក្តីសម្រេច ដីកាសម្រេច ដែលចេញដោយស្ថាប័ន ក្រសួង អង្គភាពរដ្ឋអាជ្ញាធរខេត្ត/រាជធានី ម្ចាស់គម្រោងនៅតែមានកាតព្វកិច្ចត្រូវគោរពតាមកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមួយនឹងក្រសួងបរិស្ថានអនុលោមតាមច្បាប់នេះ ។

**មាត្រា ៩._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាសេនាធិការផ្ទាល់ របស់ក្រសួងបរិស្ថាន ។

អង្គភាពអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានរចនាសម្ព័ន្ធចាត់តាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការរៀបចំ និងប្រព្រឹត្តទៅ នៃអង្គភាពអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបង្កើតឡើងក្រោយពេលច្បាប់នេះចូលជាធរមាន ។

**មាត្រា ១០._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ចដូចខាងក្រោម៖

-ទទួលបន្ទុកអនុវត្តច្បាប់នេះ ក្រោមការត្រួតពិនិត្យពីក្រសួងបរិស្ថាន

-ទទួលបន្ទុកជ្រើសរើសគម្រោងដែលស្នើសុំ កំណត់វិសាលភាពនៃគម្រោង និងលក្ខ-ខណ្ឌនៃការប្រតិបត្តិ ពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងឯកសារទាំងអស់ដែលពាក់ព័ន្ធនិងធានាឲ្យមានការចូលរួមជាសាធារណៈអនុលោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

-ចុះអង្កេតនិងតាមដានរាល់សកម្មភាពគម្រោងទៅតាមផែនការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងបរិស្ថាន ក្រោយពីម្ចាស់គម្រោងទទួលបានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាការគោរពតាមច្បាប់នេះ ។

**មាត្រា ១១._**

ក្រសួងបរិស្ថានជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម៖

-បង្កើតគណៈកម្មការជំនាញត្រួតពិនិត្យ ។

-តែងតាំងសមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ។

-ចេញលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិញ្ញាបនប្រតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

-អនុម័តគោលការណ៍ណែនាំស្តីពីលក្ខណៈវិនិច្ឆ័យការជ្រើសរើសគម្រោង ។

-កំណត់លក្ខណៈវិនិច្ឆយនៃវិសាលភាពនៃគម្រោង និងលក្ខខណ្ឌប្រតិបត្តិការងារ ។

-អនុម័តគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន ។

-ប្រើប្រាស់ និងអនុវត្តគោលការណ៍នានាដែលបានឯកភាព និងអនុវត្តដោយក្រសួងបរិស្ថានស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន ។

-អនុម័តគោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈ ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

-ចេញប្រកាសស្តីពីលក្ខណៈសម្បត្តិ និងការចុះបញ្ជីទីប្រឹក្សានៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

-អនុម័តក្របខ័ណ្ឌវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន សម្រាប់គោលការណ៍ណែនាំរបស់ខ្លួនស្តីពី វិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

**មាត្រា ១២._**

មន្ត្រីអធិការកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន មានភារកិច្ចដូចខាងក្រោម៖

-ធ្វើអធិការកិច្ចលើការអនុវត្តបទប្បញ្ញត្តិនានា ទាក់ទងនឹងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថានច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ ។

-ធ្វើអធិការកិច្ចលើការគោរពតាមល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថាន ដូចដែលបានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិ កិច្ចសន្យា ឬស្តង់ដារ និងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធ ។

-ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិក ស្តីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រាដទៃទៀត ស្តីពីគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ។

-តម្រូវឲ្យអ្នករដ្ឋបាល និយោជិត និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ផ្តល់នូវរាល់ព័ត៌មាន និង/ឬ កំណត់ត្រាទាំងអស់ នៃកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

-មានសិទ្ធិចូលទៅក្នុងទីបរិវេណទីតាំងគម្រោង ដើម្បីអនុវត្តសិទ្ធិអំណាចអធិការកិច្ចនៅទីកន្លែងដែលសង្ស័យថាមានអំពើល្មើសច្បាប់ ឬបទប្បញ្ញត្តិ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថានដោយប្រមូលវត្ថុតាង ។

-ជួបជាមួយប្រធានក្រុមប្រឹក្សាភិបាល និងអ្នករដ្ឋបាលនៃគម្រោងអភិវឌ្ឍន៍ឲ្យបានយ៉ាងហោចមួយលើកក្នុង១(មួយ)ឆ្នាំ ដើម្បីធ្វើការវាយតម្លៃលើការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ។

**មាត្រា ១៣._**

អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវអនុវត្តសិទ្ធិ និងបំពេញករណីយកិច្ច តាមការចាត់តាំងរបស់ក្រសួងបរិស្ថាន ដូចមានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំ ។

# ជំពូកទី ៤
# កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ផ្នែកទី១
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ

**មាត្រា ១៤._**

រាល់គម្រោងវិនិយោគ ឬអភិវឌ្ឍន៍ ត្រូវធ្វើការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន ឬការចុះកិច្ចសន្យាការពារបរិស្ថានអនុលោមទៅតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់នេះ។

ការចាត់ថ្នាក់គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវធ្វើឡើងដោយផ្អែកលើះ

- ប្រភេទនៃគម្រោងដែលត្រូវកំណត់ដោយអនុក្រឹត្យ
- និង/ឬទំហំនៃផលប៉ះពាល់បរិស្ថាន និងសង្គម នៃគម្រោង។

ចំពោះគម្រោងដែលត្រូវធ្វើផែនការគ្រប់គ្រងបរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើឡើងតាមទំហំនៃផលប៉ះពាល់បរិស្ថាន និងសង្គម នៃគម្រោង។

សេចក្តីសម្រេចធ្វើឡើងដោយក្រសួងបរិស្ថាន ក្រោមមាត្រានេះ គឺះ

១. គម្រោងត្រូវមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន

២. គម្រោងត្រូវមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន

៣. ផែនការគ្រប់គ្រងបរិស្ថាន ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន
៤. គម្រោងត្រូវមានកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា ១៥._**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវបានតម្រូវសម្រាប់៖

១. គម្រោងនានាដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ។

២.គម្រោងនានាដូចមានរៀបរាប់ ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ហើយដែលសេចក្តីសម្រេចរបស់ក្រសួងបរិស្ថានក្រោមមាត្រានោះ តម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

នៅពេលដែលគម្រោងដែលបានស្នើឡើង ត្រូវបានតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង អ្នកស្នើគម្រោងត្រូវធ្វើសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថានស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានព្រមទាំងលក្ខខណ្ឌតម្រូវការនៃការចូលរួមជាសាធារណៈ ។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការចេញល័ក្ខខ័ណ្ឌការងារស្តាពរសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដោយអនុលោមតាមគោលការណ៍ណែនាំដែលចេញដោយក្រសួងបរិស្ថាន ។

ខ្លឹមសារ និងទម្រង់ទូទៅ និងតាមផ្នែក សម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៦._**

ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវធ្វើឡើងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីពេលទទួលបានរបាយការណ៍នោះ ។

ករណីក្រសួងបរិស្ថានខកខាន មិនបានផ្តល់យោបល់ ឬឆ្លើយតបតាមរយៈពេលកំណត់ខាងលើ ចាត់ទុកថារបាយការណ៍វាយ តម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញបំពេញត្រឹមត្រូវតាមការកំណត់របស់ច្បាប់នេះ។

ក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលម្ចាស់គម្រោងបានកែសម្រួល ក្នុងរយៈពេល ៦០ ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា ១៧._**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវបានតម្រូវសម្រាប់៖

១.គម្រោងនានាដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ។

២.គម្រោងនានា ដែលបានរៀបចំវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ហើយដែលសេចក្តីសម្រេចរបស់ក្រសួងបរិស្ថានក្រោមមាត្រានោះ តម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

នៅពេលដែលគម្រោងស្នើសុំ ត្រូវបានតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ អ្នកស្នើគម្រោងត្រូវធ្វើសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការចេញល័ក្ខខ័ណ្ឌការងារស្ថាពរ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដោយអនុលោមតាមគោលការណ៍ណែនាំដែលចេញដោយក្រសួងបរិស្ថាន ។

ខ្លឹមសារ និងទម្រង់ទូទៅ និងតាមផ្នែក សម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា ១៨._**

រូបវន្តបុគ្គល និងនីតិបុគ្គល ត្រូវចុះបញ្ជីនៅក្រសួងបរិស្ថានជាមុនសិន មុនប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានយកកម្រៃ ។ វិញ្ញាបនបត្រនៃការចុះបញ្ជីត្រូវមានសុពលភាពជាអតិបរិមារយៈពេល៥ឆ្នាំ ហើយអាចបន្តជាថ្មីបាន ។ គុណវុឌ្ឍិ នីតិវិធីសម្រាប់ការចុះបញ្ជី និងការបន្តការចុះបញ្ជីជាថ្មី និងលក្ខណៈវិនិច្ឆ័យរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិក្នុងការចុះបញ្ជី ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៩._**

ក្រោយពេលបញ្ចប់ល័ក្ខខ័ណ្ឌការងារ អ្នកស្នើគម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញមួយដោយអនុលោមតាមគោលការណ៍ណែនាំ ។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក៏ត្រូវបញ្ចូលផងដែរនូវផែនការគ្រប់គ្រងបរិស្ថានលម្អិត ផ្អែកលើហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការរចនាគម្រោងអភិវឌ្ឍន៍ ។

ប្រសិនបើមាននូវទិន្នន័យមូលដ្ឋាន នៅក្នុងវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញដែលទទួលបានការឯកភាពមួយផ្សេងទៀត អ្នកស្នើគម្រោងត្រូវបញ្ជូនទិន្នន័យនេះទៅក្រសួងបរិស្ថាន ។

**មាត្រា ២០._**

ក្រសួងបរិស្ថាន ត្រូវទទួលខុសត្រូវបង្កើតគណៈកម្មការជំនាញត្រួតពិនិត្យមួយ ដោយអនុលោមតាមតារាងពេលវេលា និងកិច្ចដំណើរការនានាដែលបានដាក់ចេញនៅក្នុងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

- រាល់គម្រោងអភិវឌ្ឍន៍នានា ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចាំបាច់ត្រូវមានគណៈកម្មការត្រួតពិនិត្យជំនាញមួយដែលមានសមាជិកមកពីមន្ត្រីក្រសួង

បរិស្ថាន ក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញឯករាជ្យ ដែលមានគុណសម្បត្តិ និងបទពិសោធន៍សមស្របក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

- ក្រសួងបរិស្ថានត្រូវជ្រើសរើស និងអញ្ជើញអ្នកជំនាញការជាតិ និង/ឬអន្តរជាតិ ឲ្យធ្វើជាសមាជិកគណៈកម្មការជំនាញត្រួតពិនិត្យ ដែលត្រូវបានបង្កើតឡើងជាពិសេសដើម្បីពិនិត្យទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

- សមាជិកគណៈកម្មការជំនាញត្រួតពិនិត្យ ត្រូវបានជ្រើសរើសពីគម្រោងមួយទៅគម្រោងមួយ ។ សមាជិកទាំងឡាយត្រូវបានទូទាត់ប្រាក់កម្រៃសម្រាប់ការបម្រើការងាររបស់ខ្លួន ដោយផ្អែកលើការព្រមព្រៀងរវាងក្រសួងបរិស្ថាន និងសមាជិកដោយអនុលោមតាមគោលការណ៍ណែនាំអំពីថ្លៃ និងបន្ទុកសេវាបរិស្ថាន ។ ចំណាយទាំងនេះគឺជាផ្នែកនៃថ្លៃដែលបានគិតពីអ្នកស្នើសុំគម្រោង សម្រាប់ការវាយតម្លៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## មាត្រា ២១._

ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖

- ក្រសួងបរិស្ថានមានភារកិច្ចចម្បងធ្វើការពិនិត្យ និងពិចារណាលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយផ្អែកលើមតិយោបល់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ មតិយោបល់សាធារណៈ និងគណៈកម្មការត្រួតពិនិត្យជំនាញដែលបានស្នើឡើង ។

- ក្រសួងបរិស្ថាន ត្រូវពិចារណាលើរបាយការណ៍របស់គណៈកម្មការជំនាញត្រួតពិនិត្យមុនពេលចេញវិញ្ញាបនប្រតងកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

- ក្រសួងបរិស្ថានទទួលខុសត្រូវធានានូវដំណើរការសវនាការមួយ ប្រកបដោយភាពយុត្តិធម៌ ដើម្បីផ្តល់លទ្ធភាពឲ្យមានការចូលរួមជាសាធារណៈ និងត្រូវអញ្ជើញក្រសួង ឬក្រសួង/ស្ថាប័នពាក់ព័ន្ធតាមវិស័យនានា សង្គមស៊ីវិល និងអ្នកដែលទទួលរងការប៉ះពាល់ ឲ្យចូលរួមសវនាការទាំងនោះ ព្រមទាំងផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ ។

- ក្រសួងបរិស្ថាន គឺជាទីភ្នាក់ងារដឹកនាំ និងសម្របសម្រួលជាមួយនឹងក្រសួង ឬទីភ្នាក់ងារតាមវិស័យដែលពាក់ព័ន្ធនានា រួមទាំងបណ្តាភាគីទាំងឡាយ ដែលអាចទទួលរងហេតុប៉ះពាល់ដោយផ្ទាល់ ឬប្រយោលពីគម្រោង ដើម្បីឲ្យចូលរួមសវនាការដែលបានគ្រោងទុក ។

- ដោយផ្អែកលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ការបង្ហាញជាផ្លូវការដោយអ្នកស្នើគម្រោង និងតាមរយៈមតិយោបល់ជាលាយលក្ខណ៍អក្សររបស់គណៈកម្មការត្រួតពិនិត្យជំនាញ ព្រមទាំងមតិយោបល់ពីការពិគ្រោះយោបល់ពីការចូលរួមជាសាធារណៈរបស់បណ្តាក្រសួង ឬស្ថាប័នពាក់ព័ន្ធ នោះក្រសួងបរិស្ថានត្រូវពិចារណាលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ នៃថ្ងៃធ្វើការ និងកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម ដោយពិចារណាលើលក្ខណៈ ទំហំ និងទីតាំងនៃគម្រោងអភិវឌ្ឍន៍៖

១.ចេញនូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងផែនការគ្រប់គ្រងបរិស្ថាន ។

២. បដិសេធរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

- នៅពេលរដ្ឋមន្ត្រីក្រសួងបរិស្ថាន ចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានត្រូវភ្ជាប់ល័ក្ខខ័ណ្ឌផ្សេងៗលើវិញ្ញាបនបត្រឯកភាពលើរបាយការណ៍នេះ ។

- នៅពេលក្រសួងបរិស្ថាន បដិសេធរបាយការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន ។

- ក្រសួងបរិស្ថាន ត្រូវផ្ញើសេចក្តីសម្រេចរបស់ខ្លួនរួមទាំងល័ក្ខខ័ណ្ឌ ឬហេតុផលទៅឲ្យម្ចាស់គម្រោង ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។ ក្រសួងបរិស្ថានត្រូវផ្តល់សំណៅចម្លងមួយច្បាប់នៃសេចក្តីសម្រេចរបស់ខ្លួនដល់សាធារណជន នៅលើគេហទំព័ររបស់ខ្លួន និងតាមរយៈការបោះពុម្ពផ្សាយតាមសារព័ត៌មានក្នុងតំបន់ ឬថ្នាក់ជាតិ ។

**មាត្រា ២២._**

ម្ចាស់គម្រោងដែលត្រូវបានតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬនីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវទទួលបាននូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុនសិន មុននឹងអ្នកស្នើគម្រោងចាប់ផ្តើមដំណើរការក្នុងដំណាក់កាលមុនសាងសង់ ឬដំណាក់កាលសាងសង់ ។

គម្រោងអភិវឌ្ឍន៍ណាដែលគ្មាន វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវផ្អាកសកម្មភាពទាំងអស់ រហូតទាល់តែក្រសួងបរិស្ថានបានចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួងបរិស្ថានត្រូវចេញវិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការ ក្រោយពីបានពិនិត្យ និងឯកភាពលើឯកសារវាយតម្លៃបរិស្ថានត្រឹមត្រូវចំពោះរាល់គម្រោងអភិវឌ្ឍន៍ ដែលទទួលបានកិច្ចព្រមព្រៀងសម្បទានពីរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។ វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការត្រូវបានភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថានលម្អិត ដែលជាភស្តុតាងសម្រាប់ការអនុញ្ញាតចំពោះគម្រោង និងការអនុវត្តកាតព្វកិច្ចរបស់ភាគីអ្នកស្នើគម្រោង និងក្រសួងបរិស្ថាន ។

ក្រសួងបរិស្ថានមិនអាចចេញ វិញ្ញាបនបត្រឯកភាពរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុនពេលមិនទាន់បានទទួលមតិយោបល់ជាលាយលក្ខណ៍អក្សរពីសមាជិកទាំងអស់នៃគណៈកម្មការជំនាញត្រួតពិនិត្យនោះទេ ។ មតិយោបល់ និងល័ក្ខខ័ណ្ឌដែលកំណត់ដោយសមាជិកនៃគណៈកម្មការត្រួតពិនិត្យជំនាញ ត្រូវដាក់បញ្ចូលជាល័ក្ខខ័ណ្ឌក្នុងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលចេញដោយក្រសួងបរិស្ថាន ។

វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាពសម្រាប់រយៈពេលមិនលើសពី៥(ប្រាំ)ឆ្នាំឡើយ ។

ផែនការគ្រប់គ្រងបរិស្ថានលម្អិតសម្រាប់គម្រោង ត្រូវភ្ជាប់នឹងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយត្រូវចងកាតព្វកិច្ចផ្លូវច្បាប់លើភាគីទាំងពីរ ។

ក្រសួងបរិស្ថាន ត្រូវផ្ញើវិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅឲ្យម្ចាស់គម្រោង ហើយផ្ញើសំណៅមួយច្បាប់ឲ្យទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទៅឲ្យក្រសួង ឬស្ថាប័នអនុម័តគម្រោង ។

ម្ចាស់គម្រោងត្រូវទូទាត់រាល់ថ្លៃ និងបន្ទុកសេវាទាំងអស់ដែលបានកំណត់ដោយក្រសួងបរិស្ថាន មុនពេលវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលជាធរមាន ។

ក្រសួងបរិស្ថានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ម្ចាស់គម្រោងអំពីសេចក្តីសម្រេចរបស់ក្រសួង ។ សំណៅមួយច្បាប់នៃសេចក្តីសម្រេចនេះត្រូវបង្ហោះលើគេហទំព័ររបស់ក្រសួងបរិស្ថាន ហើយសំណៅមួយច្បាប់នៃវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបង្ហោះលើគេហទំព័ររបស់ក្រសួងបរិស្ថាន ព្រមជាមួយនឹងផែនការគ្រប់គ្រងបរិស្ថាន ។

**មាត្រា ២៣._**

មុនសម្រេចផ្តល់នូវលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតនៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រសួងបរិស្ថាន សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការចូលរួមក្នុងការសម្រេច ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បីបញ្ចៀសហេតុប៉ះពាល់ជាអវិជ្ជមាន ជាអាទិ៍ ទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិភាគតិច ។

## ផ្នែកទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគម្រោងដែលកំពុងដំណើរការ

**មាត្រា ២៤._**

ក្រសួងបរិស្ថានត្រូវពិគ្រោះយោបល់ជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំសម្រាប់ប្រភេទគម្រោង ដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីតម្រូវឲ្យម្ចាស់គម្រោងទាំងនោះ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣(បី) ខែ គិតចាប់ពីពេលច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលជាធរមាន។

គោលការណ៍ណែនាំត្រូវផ្អែកលើគោលការណ៍ណែនាំស្តីពីការជ្រើសរើសគម្រោង។

ម្ចាស់គម្រោង មានរយៈពេល៦(ប្រាំមួយ) ខែ ដើម្បីគោរពតាមល័ក្ខខ័ណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថានឲ្យបានចប់ហើយដាក់ឯកសារទៅក្រសួងបរិស្ថានដើម្បីពិនិត្យ ផ្តល់យោបល់ និងឯកភាព។

ផែនការគ្រប់គ្រងបរិស្ថានដែលតម្រូវ ត្រូវបញ្ជាក់លម្អិតនូវរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានស្នើឡើង ដើម្បីកាត់បន្ថយឲ្យបានកម្រិតអប្បបរមានូវហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីធានាបាននូវគុណភាពបរិស្ថាន និងការបំពេញបានតាមស្តង់ដារបរិស្ថាន ។

ថវិកាលំអិតអំពីការប៉ាន់ស្មាននៃការចំណាយ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោងដោយត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ។

## ផ្នែកទី ៣
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃការប្រែប្រួលអាកាសធាតុ

**មាត្រា ២៥._**

រាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគ និងវាយតម្លៃពីសក្តានុពលនៃហេតុប៉ះពាល់ និងភាពងាយរងគ្រោះនៃគម្រោងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ ដែលអាចរងនូវអតុល្យភាពដោយសារលក្ខខណ្ឌបរិស្ថាន ដែលរងការប៉ះពាល់ដោយរកវិធានការកាត់បន្ថយហានិភ័យដែលអាចកើតឡើងទាំងនេះ សំដៅឈានដល់ការអភិវឌ្ឍសេដ្ឋកិច្ចដែលប្រើកាបូនតិចដែលជាទិសដៅចម្បងនៃការអភិវឌ្ឍបៃតង។

រាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលនូវ ការវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះនៃបម្រែបម្រួលអាកាសធាតុ (ដោយការប្រើប្រាស់យ៉ាងហោចណាស់នូវសេណារីយ៉ូចំនួន២នៃអាកាសធាតុអាក្រក់បំផុត) ។ ម្ចាស់គម្រោងត្រូវតែធ្វើការស្នើឡើង និងវិភាគនូវវិធានការកាត់បន្ថយផលប៉ះពាល់នៅក្នុងការសិក្សាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលកាត់បន្ថយហានិភ័យនៃបម្រែបម្រួលអាកាសធាតុ និងដាក់បញ្ចូលរាល់ផែនការឆ្លើយតបបន្ទាន់ និងជម្រើសបច្ចេកវិទ្យា ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ។

បរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍន៍ត្រូវគណនា និងដាក់បញ្ចូលនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ដោយប្រើប្រាស់ការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប ដោយមានគោលបំណងនៃការប្រើប្រាស់ការផលិត និងការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាពតម្លៃដើម្បីសម្រេចបាននូវការអភិវឌ្ឍបៃតង ។

បម្រែបម្រួលអាកាសធាតុនាំឱ្យមានក្របខណ្ឌមួយដែលខុសប្លែកពីមុន សម្រាប់ការពិចារណាលើការប្រើប្រាស់ទឹក និងតម្រូវការថាមពល ។ ម្ចាស់គម្រោងគួរតែស្វែងរកនូវជម្រើសថាមពលដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប តម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីកត្តាអាកាសធាតុ និងលទ្ធផលនៃការប្រែប្រួលនៅក្នុងបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោង ។

# ផ្នែកទី ៤
# ការវាយតម្លៃហេតុប៉ះពាល់ជាបណ្តុំ

**មាត្រា ២៦.-**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគនិងវាយតម្លៃពីបណ្តុំនៃហេតុប៉ះពាល់ ដែលបង្កឡើងដោយដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគតនៅជុំវិញនៃទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឲ្យមានហេតុប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន ឬសង្គម ។

នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃហេតុប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីផលប៉ះពាល់បន្ថែម ផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃហេតុហេតុប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀស បណ្តុំនៃហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ ។

# ផ្នែកទី ៥
# ការវាយតម្លៃហេតុប៉ះពាល់សុខភាព

**មាត្រា ២៧.-**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាព ដែលមានជាអាទ៍៖

-ទិន្នន័យមូលដ្ឋានស្តីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងហេតុប៉ះពាល់ ។

-ការពិពណ៌នាអំពីហេតុប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន ។

-វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ហេតុប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឲ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន ។

-បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងហេតុប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែងសម្រាប់គម្រោង ។

ម្ចាស់គម្រោងត្រូវលើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និង

ប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ-គីមីសាស្ត្រ ជីវសាស្ត្រ វិទ្យុសកម្ម និងផ្នែកសម្លេងរំខាន ។

ម្ចាស់គម្រោងត្រូវកំណត់ និងវាយតម្លៃពីគ្រោះហានិភ័យ និងសក្តានុពលនៃហេតុប៉ះពាល់ទៅលើសុវត្ថិភាពនិងសុខភាពរបស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោងប្រតិបត្តិគម្រោង និងបញ្ចប់គម្រោងព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងហេតុប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ ។

# ជំពូកទី ៥
# ការចូលរួមជាសាធារណៈ

**មាត្រា ២៨.**_

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ គឺដើម្បីធានាថា អ្នកដែលទទួលរងហេតុប៉ះពាល់ និងភាគីពាក់ព័ន្ធ បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង ព្រមទាំងមានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងគម្រោង រួមទាំងឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង ។ ការពិពណ៌នាពីកិច្ចដំណើរការផែនការពិគ្រោះយោបល់ និងអ្នកចូលរួមក្នុងកិច្ចដំណើរការនេះត្រូវដាក់បញ្ចូលក្នុងល័ក្ខខ័ណ្ឌការងារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ម្ចាស់គម្រោងត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី៖

- កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងសង្គម ។
- ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេច ។
- ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីហេតុប៉ះពាល់សង្គម និងបរិស្ថាន ។
- ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយហេតុប៉ះពាល់នានា ។

ម្ចាស់គម្រោងត្រូវធានាថា រាល់អ្នកដែលទទួលរងហេតុប៉ះពាល់ រដ្ឋបាលមូលដ្ឋាន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវទទួលបានព័ត៌មានអំពីគម្រោងជាភាសាខ្មែរ និងទទួលបានឱកាស ក្នុងការចូលរួមយ៉ាងពេញលេញ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ ។

កិច្ចប្រជុំត្រូវបានរៀបចំដោយម្ចាស់គម្រោង ដោយពិគ្រោះយោបល់ជាមួយនឹងក្រសួងបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

នីតិវិធី នៃការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៩._**

ការចូលរួមជាសាធារណៈទាំងអស់ត្រូវកត់ត្រាទុកនិងពិចារណាដោយម្ចាស់គម្រោង ក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោងត្រូវរាយការណ៍អំពីសេចក្តីលំអិតនៃហេតុប៉ះពាល់របស់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន ។

ប្រសិនបើម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ម្ចាស់គម្រោងត្រូវផ្តល់ហេតុផលបដិសេធទាំងនោះក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានច្បាស់ ។

**មាត្រា ៣០._**

កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវបានយកមកប្រើ ដើម្បីកំណត់វិធានការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ។

កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថា អ្នកដែលទទួលរងហេតុប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយហេតុប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឲ្យបានកម្រិតអប្បបរមាដើម្បីធានាថា សំណងលើការបាត់បង់ទ្រព្យសម្បត្តិត្រូវបានដោះស្រាយដោយយុត្តិធម៌សមស្របជាមុនសិន និងទទួលយកបានតាមតម្លៃទីផ្សារ ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ ។

នីតិវិធីនៃការផ្លាស់ប្តូលំនៅថ្មី និងដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងហេតុប៉ះពាល់ត្រូវកំណត់ដោយអនុក្រឹត្យ ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាតដល់សហគមន៍ទទួលរងហេតុប៉ះពាល់ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

កិច្ចដំណើរការចូលរួមសាធារណៈត្រូវធានាថា ការយល់ព្រមរបស់សហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ត្រូវផ្អែកលើគោលការណ៍យល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ ។

**មាត្រា ៣១._**

ក្រសួងបរិស្ថានត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងឯកសារពាក់ព័ន្ធ រួមមាន វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធ និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់។

ថ្លៃចំណាយលើការផ្សព្វផ្សាយឯកសារជាសាធារណៈ រាប់ទាំងគេហទំព័រ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ក្រសួងបរិស្ថានត្រូវកំណត់គោលការណ៍ណែនាំបន្ថែម ស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ។

## ជំពូកទី ៦
## ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង

**មាត្រា ៣២._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ជាអាជ្ញាធរត្រួតពិនិត្យលើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ ។

**មាត្រា ៣៣._**

ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង ។

ផែនការគ្រប់គ្រងបរិស្ថានត្រូវដាក់បញ្ចូលក្នុងល័ក្ខខ័ណ្ឌតម្រូវ នៃការការពារ ការកាត់បន្ថយ ការឃ្លាំមើល និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

រាល់គម្រោងអភិវឌ្ឍន៍ ដែលទទួលបានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវគោរពតាមល័ក្ខខ័ណ្ឌ និងខ្លឹមសារ ដែលមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងល័ក្ខខ័ណ្ឌដែលមានចែងក្នុងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៣៤._**

រាល់គម្រោងអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុងដែលត្រូវធានាឲ្យមាននូវនីតិវិធី និងវិធីសាស្ត្រឃ្លាំមើលដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ក្នុងករណីហេតុប៉ះពាល់បរិស្ថាន មានកម្រិតលើសពីស្តង់ដារកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានតម្រូវឲ្យចាត់វិធានការកែតម្រូវហេតុប៉ះពាល់ភ្លាមៗ ឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីឃ្លាំមើល ត្រូវទទួលបានការឯកភាពពីក្រសួងបរិស្ថាន ហើយរយៈពេលត្រូវកំណត់ឡើងសារជាថ្មី ដើម្បីធ្វើការកែតម្រូវ ឬកែលម្អចាំបាច់ ដោយត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ។

ថ្លៃចំណាយទាំងអស់ក្នុងការកែតម្រូវ ឬកែលម្អវិធានការកាត់បន្ថយហេតុប៉ះពាល់ និង កម្មវិធីឃ្លាំមើលគម្រោង ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់០៣ខែម្តង ហើយ បញ្ជូនមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។ អង្គភាព វាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផលនៃការ អង្កេតតាមដានរបស់ម្ចាស់គម្រោង ។

**មាត្រា ៣៥._**

អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ត្រូវមានសិទ្ធិទទួលបានព័ត៌មានស្តី ពីហេតុប៉ះពាល់អវិជ្ជមានលើជីវិតរស់នៅ ទ្រព្យសម្បត្តិ និងសិទ្ធិទទួលបានក្នុងការប្រើប្រាស់ ធនធានធម្មជាតិ និងជីវភាពរស់នៅនិងសិទ្ធិទទួលបាននូវព័ត៌មានអំពីស្ថានការណ៍បរិស្ថាននៃ គម្រោង និងល័ក្ខខ័ណ្ឌតម្រូវតាមច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា និងវិញ្ញាបនបត្រឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហានិង ក្តីកង្វល់បរិស្ថាន និងសង្គមជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ហាទាំងនោះត្រូវដោះស្រាយដោយអនុគណៈកម្មការថ្នាក់ក្រោម និងអាចបន្តមកគណៈ កម្មការអន្តរក្រសួង ដែលបង្កើតឡើងជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញាតិហើយដោះស្រាយ បញ្ហាបរិស្ថាន និងសង្គមដែលពាក់ព័ន្ធ តាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់ អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ។

**មាត្រា ៣៦._**

គម្រោងនានាដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រកាស ដែលនាំឱ្យមានផលប៉ះ ពាល់គួរឱ្យកត់សម្គាល់ដល់សង្គម និងបរិស្ថាន ត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានខាងក្រៅ ដូចមានចែងក្នុងប្រកាស។ សវនករបរិស្ថានត្រូវៈ

- ជួយជ្រោមជ្រែងក្នុងការកត់ត្រាកំណត់ត្រាបរិស្ថានឲ្យបានត្រឹមត្រូវនិងពេញលេញ។
- ផ្តល់មតិយោបល់សវនកម្មវិជ្ជាជីវៈ ជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវ ទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោង ឬការប្រតិបត្តិការរបស់ គម្រោង ។
- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្ត នីតិវិធីនៃការគ្រប់គ្រង និងការឃ្លាំមើលបរិស្ថានផ្ទៃ ក្នុង ព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ ។
- ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតី និងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ ខ្លួន ។

សំណៅមួយច្បាប់នៃរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយសវនករបរិស្ថានខាង ក្រៅ ត្រូវប្រគល់ជូនក្រសួងបរិស្ថាន ។

**មាត្រា ៣៧._**

គម្រោងអភិវឌ្ឍន៍នីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ដូចតទៅ៖

- របាយការណ៍រៀងរាល់០៣ (បី)ខែ ត្រូវបញ្ជូនទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន ឃ្លាំមើល និងការគ្រប់គ្រងបរិស្ថាន។
- ក្នុងរយៈពេល០៣(បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្តីពីបរិស្ថាន។
- ផ្តល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំនៃគម្រោងដល់សាធារណជន តាមការស្នើសុំដោយឥតគិតថ្លៃ ។
- ផ្តល់សំណៅអេឡិចត្រូនិកដែលត្រូវបង្ហោះលើគេហទំព័រ ជាសាធារណៈរបស់ក្រសួងបរិស្ថាន និងដោយម្ចាស់គម្រោង នៅលើគេហទំព័រសាធារណៈមួយ ។

**មាត្រា ៣៨._**

គម្រោងអភិវឌ្ឍន៍ ដែលមានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆមាស ទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាក់ទងនឹងការឃ្លាំមើល និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍ភ្លាមៗ អំពីបញ្ហាបរិស្ថានសំខាន់ដល់អាជ្ញាធរដែលពាក់ព័ន្ធ និងដែលមានការទទួលខុសត្រូវ និងដល់សាធារណជន ដើម្បីជៀសវាងហេតុប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម ។

តម្លៃម្ចាស់គម្រោងត្រូវផ្តល់ព័ត៌មានដល់ក្រសួងបរិស្ថាន តាមដែលក្រសួងបរិស្ថានអាចស្នើសុំដោយសមហេតុផលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ។

# ជំពូកទី ៧
# ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងហេតុប៉ះពាល់ឆ្លងដែន
## ផ្នែកទី ១
## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា ៣៩._**

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ជំរុញការអភិវឌ្ឍបៃតងដែលធានាដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈការវាយតម្លៃ ការពង្រឹង និងការបញ្ជ្រាបគោលនយោបាយ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចដំណើរការសម្រេចចិត្តទៅលើគម្រោងអភិវឌ្ឍន៍នានា។

គោលបំណងនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សំដៅ៖

-ផ្តល់ឱកាសក្នុងការណែនាំយ៉ាងសកម្មនូវ ការអភិវឌ្ឍនៅក្នុងលក្ខណៈប្រកបដោយនិរន្តរភាព ។

-ជំរុញការពិចារណាលើជម្រើសដ៏ទូលំទូលាយតម្លៃ ។

-ជំរុញការវិភាគហេតុប៉ះពាល់ទ្រង់ទ្រាយធំរួមទាំងហេតុប៉ះពាល់សុខភាព និងហេតុប៉ះពាល់ឆ្លងដែនដែលពាក់ព័ន្ធនឹងក្តីកង្វល់ថ្នាក់ជាតិក្នុងតំបន់ និងនៅលើសកលលោក ។

-ជួយដល់ការអនុវត្តផែនការបរិស្ថានជាតិផែនការសកម្មភាពបរិស្ថានជាតិ ជំរុញការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងកសាងសមត្ថភាពវាយតម្លៃបរិស្ថាន ។

**មាត្រា ៤០._**

ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ តាមវិស័យទៅលើគោលនយោបាយផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសំដៅលើវិស័យអភិវឌ្ឍន៍សំខាន់ៗជាអាទិ៍ ថាមពល ដឹកជញ្ជូន ឧស្សាហកម្មទាញយក (រ៉ែ ធនធានទឹក រុក្ខាប្រមាញ់) ទេសចរណ៍ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យពាក់ព័ន្ធផ្សេងទៀត ។

ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ត្រូវទទួលខុសត្រូវពិនិត្យការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងត្រូវផ្តល់មតិយោបល់ដល់ទីភ្នាក់ងារពាក់ព័ន្ធ ដោយតម្រូវឲ្យមានការចូលរួមជាសាធារណៈ ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវជំរុញដល់ការអភិវឌ្ឍបៃតង និង ការអភិវឌ្ឍប្រកបដោយចិរភាព ទាំងបរិស្ថាន និងសង្គម តាមរយៈការព្យាករណ៍ និងកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរួមបញ្ចូលហេតុប៉ះពាល់សុខភាព ចាប់ពីដំណាក់កាលរចនាគម្រោងធ្វើផែនការ និងកំណត់ពីជម្រើសគុណភាពបរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិដោយសន្សំសំចៃ និងទទួលបានទិន្នផលខ្ពស់ ព្រមទាំងធានាដល់ការអនុវត្តគោលនយោបាយ និងផែនការឲ្យមានស្លេរភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ និងកិច្ចការពារបរិស្ថាននិងសង្គម ។

ការរួមបញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់កម្រិតគម្រោង និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសម្រាប់កម្រិតគោលនយោបាយ គឺសំដៅដល់ការអភិវឌ្ឍបៃតង ជាពិសេសការដោះស្រាយការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមនៃការរៀបចំផែនការ។ ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវរៀបចំឲ្យប្រើប្រាស់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីវាយតម្លៃទំនាក់ទំនងរវាងបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌នៃផែនការតាមវិស័យ ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មានតួនាទីសំខាន់ក្នុងការកំណត់វត្ថុបំណងសម្រាប់វិស័យជាក់លាក់ ព្រមទាំង កម្មវិធី និងផែនការរបស់រាជរដ្ឋាភិបាល ។

# ផ្នែកទី២
# ហេតុប៉ះពាល់បរិស្ថានឆ្លងដែន

**មាត្រា ៤១._**

គម្រោងដែលអាចមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

ក្រសួងបរិស្ថាន ត្រូវបង្កើតគោលការណ៍ណែនាំស្តីពីលក្ខណវិនិច្ឆ័យកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

**មាត្រា ៤២._**

នៅពេលគម្រោងចាប់ផ្តើមឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ក្រសួងបរិស្ថានត្រូវបញ្ជូនរបាយការណ៍ពិនិត្យជ្រើសរើសគម្រោង ដល់ប្រទេសទាំងឡាយដែលទទួលរងហេតុប៉ះពាល់ ដោយជូនដំណឹងប្រទេសទាំងនោះអំពីគម្រោងអភិវឌ្ឍន៍ស្នើសុំ ។ ក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការពិភាក្សាជាមួយបណ្តាប្រទេសទាំងនោះ អំពីនីតិវិធីនិងពេលវេលា ដើម្បីផ្តល់មតិយោបល់អំពីគម្រោងស្នើសុំ ។

ប្រទេសកម្ពុជាត្រូវផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ និងសាធារណជនឲ្យចូលរួមក្នុងនីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ទាក់ទងនឹងសកម្មភាពស្នើឡើង ហើយត្រូវធានាផ្តល់ឱកាសដល់សាធារណជននៃប្រទេស ដែលអាចទទួលរងហេតុប៉ះពាល់ទាំងនោះ ដូចគ្នានឹងសាធារណជននៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសស្នើគម្រោង។

នៅពេលក្រសួងបរិស្ថានទទួលបានរបាយការណ៍ពិនិត្យជ្រើសរើស សម្រាប់គម្រោងក្នុងប្រទេសកម្ពុជាដែលមានសញ្ញាណ នៃហេតុប៉ះពាល់បរិស្ថានដល់ប្រទេសមួយទៀត ក្រសួងបរិស្ថានត្រូវជូនដំណឹងដល់អាជ្ញាធរនៃប្រទេសនោះ ដើម្បីប្រមូល និងប្រៀបធៀបការឆ្លើយតបពីអាជ្ញាធរ/ទីភ្នាក់ងារពាក់ព័ន្ធ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងឲ្យដាក់ការឆ្លើយតបជាផ្លូវការមកក្រសួងបរិស្ថានកម្ពុជា (ប្រទេសស្នើគម្រោង)។ ករណីពុំបានទទួលការឆ្លើយតបក្នុងរយៈពេលជាកំណត់នេះនោះទេ កម្ពុជាសន្មត់ថា ប្រទេសនោះមិនចង់ចូលរួមក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនតទៅទៀតទេ។

នៅពេលក្រសួងបរិស្ថានទទួលរបាយការណ៍ជ្រើសរើសគម្រោង (ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ពីប្រទេសមួយសម្រាប់គម្រោងមួយ ដែលមានហេតុប៉ះពាល់បរិស្ថានជាក់លាក់មកលើប្រទេសកម្ពុជា ភាគីកម្ពុជាត្រូវបើកកិច្ចពិភាក្សាភ្លាមៗជាមួយនឹងប្រទេសនោះស្តីពីនីតិវិធី និងពេលវេលាសម្រាប់ការផ្តល់មតិយោបល់ អំពីគម្រោងស្នើឡើងនោះ។

អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសស្នើគម្រោងអនុញ្ញាតឲ្យភាគីកម្ពុជាប្រមូល និងប្រៀបធៀបការឆ្លើយតបពីអាជ្ញាធរ/ស្ថាប័ន/ភាគីពាក់ព័ន្ធនៃប្រទេសទទួលរងហេតុប៉ះពាល់ ហើយត្រូវ

ដាក់ការឆ្លើយតបផ្លូវការទៅនឹងសេចក្ដីជូនដំណឹងទៅអាជ្ញាធរជាកំណត់ នៃប្រទេសស្នើគម្រោង ដើមនោះនៅក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីទទួលសេចក្ដីជូនដំណឹង ។ ករណីការ ឆ្លើយតបមិនបានទទួលក្នុងរយៈពេលជាកំណត់នោះ ប្រទេសស្នើគម្រោងអាចសន្មត់ថា កម្ពុជា មិនចង់ចូលរួមក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនតទៅទៀតទេ ។

មតិយោបល់ដែលទទួលបានពីប្រទេសមួយផ្សេងទៀត ស្ដីពីរបាយការណ៍ជ្រើសរើស គម្រោង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវពិចារណាដោយក្រសួងបរិស្ថាន។ តំណាងនៃប្រទេសដទៃទៀតដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង មានសិទ្ធិមានវត្ត មានក្នុងបទបង្ហាញផ្លូវការ និងសវនាការសាធារណៈស្ដីពីគម្រោងនៅកម្ពុជា ហើយទទួលបាន ឱកាសសម្ដែងមតិយោបល់របស់ខ្លួន នៅចំពោះមុខសាធារណជនទូទៅ ។

សោហ៊ុយចំណាយរបស់រដ្ឋាភិបាលកម្ពុជា ចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្លងដែន ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

## មាត្រា ៤៣._

ម្ចាស់គម្រោងត្រូវលើកវិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីលុបបំបាត់ បន្ធូរបន្ថយ ឬកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងដែលបានព្យាករណ៍ទុក ។ វិធានការទាំងនេះត្រូវពិនិត្យ និង ផ្ដល់មតិយោបល់ដោយសាធារណជននៅក្នុងប្រទេសកម្ពុជា ដែលអាចទទួលរងហេតុប៉ះ ពាល់ អនុលោមតាមនីតិវិធី និងពេលវេលាដែលបានព្រមព្រៀងគ្នា ។

ម្ចាស់គម្រោងត្រូវទទួលយកមតិយោបល់ដែលទទួលបានពីភាគីទាំងអស់ ដែលទទួល រងហេតុប៉ះពាល់ ហើយរៀបចំផែនការគ្រប់គ្រងបរិស្ថានសមស្រប ដើម្បីគ្រប់គ្រងលើហេតុប៉ះ ពាល់ឆ្លងដែនដែលបានព្យាករណ៍ទុក ។

ក្នុងករណីមានគ្រោះថ្នាក់ ឬការខូចខាតចំពោះអ្នកដែលទទួលរងហេតុប៉ះពាល់ឆ្លងដែន ម្ចាស់គម្រោងត្រូវទទួលខុសត្រូវលើសំណងការខូចខាត ទាំងប្រជាជនកម្ពុជា និងប្រជាជននៃ ប្រទេសដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង។ ថ្លៃគ្រោះថ្នាក់ និងថ្លៃនៃការខូចខាត ជាទំនួលទទួលខុសត្រូវរបស់ម្ចាស់គម្រោង ។

## មាត្រា ៤៤._

ប្រទេសពាក់ព័ន្ធត្រូវរួមគ្នាកំណត់វិធីសាស្ត្រអង្កេតតាមដាន ឃ្លាំមើលសញ្ញាណនៃហេតុ ប៉ះពាល់បរិស្ថានឆ្លងដែន ដែលអាចកើតមាននៅក្នុងដំណាក់កាលរចនាគម្រោងការសាងសង់ ការប្រតិបត្តិនិងការបញ្ចប់ការងារទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ស្នើសុំនិងផែនការគ្រប់គ្រងបរិស្ថាន។

ម្ចាស់គម្រោងនៃប្រទេសស្នើសុំគម្រោង ត្រូវដាក់របាយការណ៍អង្កេតតាមដានបរិស្ថាន ជារៀងរាល់ឆ្នាំ និងត្រូវធ្វើសវនកម្មដោយក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានត្រូវផ្ញើសំណៅនៃ របាយការណ៍អង្កេតតាមដានបរិស្ថានជូនអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដែលទទួលរងហេតុ ប៉ះពាល់ ។

លទ្ធផលនៃការអង្កេតតាមដានគម្រោង ត្រូវតែមានគោលដៅក្នុងការធានាឱ្យបាននូវការ អនុលោមតាមល័ក្ខខ័ណ្ឌនានាដែលបានដាក់ចេញ នៅក្នុងលិខិតអនុញ្ញាតឬលិខិតឯកភាពលើ គម្រោង និងនៅក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងនោះក៏ដូចជានៅក្នុង ប្រសិទ្ធភាពនៃ

វិធានការកាត់បន្ថយ[ការប៉ះពាល់]ផ្សេងៗ នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសដែលអាចទទួលរងហេតុប៉ះពាល់។

# ជំពូកទី ៨
# ថ្លៃសេវា និងបន្ទុកផ្សេងៗ

**មាត្រា ៤៥._**

ម្ចាស់គម្រោងត្រូវទទួលរ៉ាប់រងបង់រាល់ការចំណាយទាំងអស់ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សេវាសម្រាប់ចាត់ថ្នាក់គម្រោង សេវាសម្រាប់កំណត់លើវិសាលភាពនៃការសិក្សា និងក្នុងការចំណាយលើកិច្ចដំណើរការចូលរួមជាសាធារណៈ និងសេវាសម្រាប់ការ ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍របស់ក្រសួងបរិស្ថាន រួមទាំងគណៈកម្មការត្រួតពិនិត្យជំនាញ ។

ម្ចាស់គម្រោងត្រូវទទួលរ៉ាប់រងដោយផ្ទាល់ខ្លួន ក្នុងការបង់ថ្លៃចំណាយលើការរៀបចំ ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ត្រួតពិនិត្យ និងអង្កេតតាមដានលើការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ថ្លៃសេវា និងបន្ទុកផ្សេងៗ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៤៦._**

នៅពេលចេញវិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានមានភារកិច្ចប្រមូលថ្លៃ និងបន្ទុកសេវា ដូចមានចែងនៅក្នុងប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង់ថ្លៃសេវាការងារតម្លៃ ម្ចាស់គម្រោងត្រូវបង់វិភាគទានលើថ្លៃនិងបន្ទុកសេវាទៅឱ្យក្រសួងបរិស្ថានជារៀងរាល់ឆ្នាំ ដើម្បីប្រើប្រាស់សម្រាប់ការកសាងសមត្ថភាព ដល់មន្ត្រីបរិស្ថានថ្នាក់ស្រុកនិងខេត្ត និងដើម្បីផ្តល់លទ្ធភាពដល់ក្រសួងបរិស្ថានក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្នុងការត្រួតពិនិត្យរបាយការណ៍តាមដានត្រួតពិនិត្យ ក៏ដូចជាឆ្លើយតបចំពោះសំណើឱ្យមានការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងក្នុងការអនុវត្តការតាមដានត្រួតពិនិត្យលើការអនុលោមតាមច្បាប់ជាប្រចាំ ទាំងនៅក្នុងអំឡុងពេលនៃដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិការគម្រោង ។

**មាត្រា ៤៧._**

ម្ចាស់គម្រោងត្រូវបង់មូលនិធិបរិស្ថាន និងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន។

មូលនិធិបរិស្ថាន និងសង្គមត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការស្តារបរិស្ថាន អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍសង្គមនៅក្នុង និងជុំវិញតំបន់ដែលគម្រោងតាំងនៅ ។ មូលនិធិបរិស្ថាន និងសង្គម ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយអនុក្រឹត្យ ។

ម្ចាស់គម្រោងត្រូវបានតម្រូវឱ្យបង់វិភាគទានជាអប្បបរមា ១ ភាគរយ នៃថ្លៃគម្រោង ឬទំហំនៃការខូចខាត ។ ៥០ (ហាសិប) ភាគរយ នៃវិភាគទាននេះត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាន ដែលមានចែងនៅក្នុងមាត្រា ១៩ នៃច្បាប់ស្តីពីកិច្ចការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ហើយ៥០ (ហាសិប) ភាគរយ ទៀត ត្រូវបង់ចូលមូលនិធិបរិស្ថាន និងសង្គមនៃក្រសួងបរិស្ថាន មុនពេលចាប់ផ្តើមនៃគម្រោង។

ម្ចាស់គម្រោងត្រូវបង់វិភាគទានចូលមូលនិធិទាំងនេះ អនុលោមតាមគោលការណ៍ណែនាំ របស់ក្រសួងបរិស្ថាន ។

**មាត្រា ៤៨._**

ក្រសួងបរិស្ថានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬក្រុងនិងទីភ្នាក់ងារទទួលខុសត្រូវ បរិស្ថាន និងរដ្ឋបាលមូលដ្ឋាន មានសិទ្ធិធ្វើសំណើសុំរង្វាន់ ឬវិញ្ញាបនបត្ររង្វាន់ ឬទម្រង់ពាក្យទទួលស្គាល់ដទៃទៀត ចំពោះការសម្រេចបាននូវកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា ឲ្យទៅបុគ្គល អង្គភាព ក្រុមហ៊ុន ឬអង្គការណាមួយដែលមានស្នាដៃឆ្នើមក្នុងសកម្មភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

## ជំពូកទី ៩
## នីតិវិធីបណ្តឹង

**មាត្រា ៤៩._**

បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវរាយការណ៍ អំពីបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មកអាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ ឬស្រុក/ខណ្ឌ ឬខេត្ត/រាជធានី ឬមន្ទីរបរិស្ថានបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ។

បន្ទាប់ពីបានទទួលសេចក្តីរាយការណ៍ អាជ្ញាធរមូលដ្ឋានត្រូវរាយការណ៍បន្តជូន មន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានយ៉ាងយូរបំផុត៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីរាយការណ៍នោះ ។ ក្រោយពីបានទទួលសេចក្តីរាយការណ៍ មន្ទីរបរិស្ថានខេត្ត/រាជធានីឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវធ្វើការស៊ើបអង្កេត និងចំណាត់ការ លើពាក្យបណ្តឹងនោះ ។

**មាត្រា ៥០._**

នៅពេលដែលភាគីទទួលរងផលប៉ះពាល់ ដោយសារបទល្មើសការវាយតម្លៃហេតុប៉ះពាល់បរិស្ថានកម្រិតស្រាល បានប្តឹងតវ៉ាមកក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើការដោះស្រាយវិវាទនោះអោយចប់សព្វគ្រប់ក្នុងអំឡុងពេល យ៉ាងយូរបំផុត ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។ ក្រុមហ៊ុនត្រូវតែពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាក់ទងនឹងនីតិវិធីក្នុងការដោះស្រាយវិវាទនោះ ។

ប៉ុន្តែនៅពេលដែលភាគីរងផលប៉ះពាល់ មិនពេញចិត្តនឹងសេចក្តីសម្រេច ឬដំណោះស្រាយរបស់ក្រុមហ៊ុន ភាគីនោះអាចប្តឹងតវ៉ាមករដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដំណោះស្រាយ ឬសេចក្តីសម្រេចនោះ។

រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការដើម្បីធ្វើការដោះស្រាយវិវាទនោះ ។ ក្នុងករណីដែលភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន ភាគីអាចប្តឹងតវ៉ាបន្តមកតុលាការមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានដំណោះស្រាយ ឬសេចក្តីសម្រេចនោះ។

ម្ចាស់គម្រោង ឬក្រុមហ៊ុន ត្រូវមានសៀវភៅកំណត់ត្រាពាក្យបណ្តឹង ដែលត្រូវបានទទួលស្គាល់ដោយក្រសួងបរិស្ថាន។ ក្រសួងបរិស្ថាន ឬស្ថាប័នតុលាការអាចពិនិត្យសៀវភៅកំណត់ត្រាពាក្យបណ្តឹងនេះ គ្រប់ពេលវេលា។

ថ្លៃចំណាយទាំងអស់ក្នុងការដោះស្រាយវិវាទទាំងតាមក្រៅប្រព័ន្ធតុលាការ និងតាមផ្លូវតុលាការជាបន្ទុករបស់ម្ចាស់គម្រោង។

**មាត្រា ៥១._**

វិវាទវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែធ្វើការដោះស្រាយដោយក្រសួងបរិស្ថានជាមុនសិន មុននឹងឈានដល់ការដោះស្រាយតាមប្រព័ន្ធតុលាការ លើកលែងតែបទល្មើសនោះមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ។

ចំពោះបែបបទ និងនីតិវិធីក្នុងការដោះស្រាយវិវាទវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា ៥២._**

ភាគីណាមួយ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផ្លូវរដ្ឋបាល របស់មន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីនៃក្រសួងបរិស្ថានក្នុង រយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនោះ ។

រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានពាក្យបណ្តឹង ។

ក្នុងករណីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន ភាគីអាចប្តឹងតវ៉ាបន្តទៅតុលាការ ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនោះ ។

**មាត្រា ៥៣._**

ការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ពិន័យជាប្រាក់ ការរឹបអូសវត្ថុតាង សំណងការខូចខាត ការជួសជុល ការស្តារការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

ការសម្រេចពិន័យអន្តរការណ៍ ជាការព្រមាន ការកែតម្រូវ ការចាប់យកវត្ថុតាងនៃបទល្មើស និងការបង់ប្រាក់ពិន័យជាសមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានីខេត្ត។

ចំពោះទោសទណ្ឌជាការជួសជុល ការស្តារការខូចខាត ការព្យួរជាបណ្តោះអាសន្ន ការលុបលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការលុបចោលកិច្ចសន្យា ឬការបង់ប្រាក់ពិន័យជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

មន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវទទួលទណ្ឌកម្មរដ្ឋបាល បន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ៥៤._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី/ខេត្ត មានសិទ្ធិចូលរួមក្នុងដំណើរការនៃការទាមទារសំណងការខូចខាត ដែលកើតចេញពីបទល្មើសការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងដំណាក់កាលតុលាការ ។

ក្នុងករណីដែលមន្ទីរបរិស្ថានរាជធានី/ខេត្ត ពុំមានលទ្ធភាពធ្វើការគណនាពីបរិមាណនៃសំណងការខូចខាតនោះ មន្ទីរបរិស្ថានរាជធានី/ខេត្តអាចធ្វើការស្នើសុំជំនួយពីក្រសួងបរិស្ថាន ។

ការចាត់ចែងប្រាក់សំណងការខូចខាតតាមរយៈសាលក្រម ឬសាលដីកាស្ថាពរ ជាសមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី/ខេត្ត ។

**មាត្រា ៥៥._**

អាជ្ញាយុកាលនៃបទល្មើសមានដូចតទៅ៖

- ០១ ឆ្នាំ ចំពោះបទល្មើសរដ្ឋបាល
- ៥ ឆ្នាំ ចំពោះបទមជ្ឈឹម
- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ

ថិរវេលានៃអាជ្ញាយុកាល ត្រូវគិតចាប់ពីថ្ងៃដែលបណ្តឹងនោះបានដាក់មកអាជ្ញាធរមានសមត្ថកិច្ច ។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗខាងលើនេះ នាំអោយមានការចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល ។

## ជំពូកទី ១០
## មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៥៦._**

សមាសភាពមន្ត្រីនគរបាលយុត្តិធមិវាយតម្លៃហេតុប៉ះពាល់បរិស្ថានមាន៖

- មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មន្ទីរបរិស្ថានរាជធានី/ខេត្ត

**មាត្រា ៥៧._**

ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៅពេលក្រោយទៀត ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួម រវាងក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។ ចំពោះរូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយក្រសួងយុត្តិធម៌។

**មាត្រា ៥៨._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងការ ទទួលពាក្យបណ្តឹង ធ្វើការស៊ើបអង្កេត និងកសាងសំណុំរឿងប្តឹងទៅតុលាការមានសមត្ថកិច្ច ។

ការស្រាវជ្រាវ ការត្រួតពិនិត្យ ការទប់ស្កាត់ ការបង្ក្រាបបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសមត្ថកិច្ចរបស់មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសសម្បទាមន្ត្រីនគរបាលយុត្តិធម៌ ។

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ នៃបទល្មើសក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៥៩._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដែនដីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃមន្ទីរបរិស្ថានរាជធានី /ខេត្ត មានសមត្ថកិច្ចដែនដីនៅក្នុងមណ្ឌលរដ្ឋបាលរបស់ខ្លួន ។

ក្នុងករណីមានវិវាទសមត្ថកិច្ច ឬជាន់សមត្ថកិច្ចដែនដី រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានជាអ្នកសម្រេច ។ ការសម្រេចនេះបិទផ្លូវតវ៉ា ។

**មាត្រា ៦០._**

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ត្រួតពិនិត្យបទល្មើស និងបង្ក្រាបបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងករណីមានការស្នើសុំពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

**មាត្រា ៦១._**

ការអនុវត្តតួនាទីមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖

១.នៅគ្រប់ដំណាក់កាលនៃការអនុវត្តនីតិវិធីបង្ការ បង្ក្រាបបទល្មើស មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានមានតួនាទីជាម្ចាស់បណ្តឹង ម្ចាស់ករណីលើគ្រប់បទល្មើស ។

២.ក្រោយបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកការងារ ដែលមានលិខិតចាត់តាំងត្រូវមានភារៈកិច្ចការពារសំណុំរឿង ក្នុងនាមជាម្ចាស់ករណី និង/ឬ ម្ចាស់បណ្តឹងដោយការទទួលខុសត្រូវខ្ពស់។

៣.នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកជាម្ចាស់ករណី និង/ឬ ម្ចាស់បណ្តឹងត្រូវមានវត្តមានតាមដាន ចូលការពារសំណុំរឿង បំភ្លឺ ផ្តល់គ្រប់មធ្យោបាយនានាតាមផ្លូវច្បាប់ និងផ្តល់ភស្តុតាងដើម្បីជាប្រយោជន៍ ក្នុងសំណុំរឿងជាការយកចិត្តទុកដាក់ ការទទួលខុសត្រូវលើនីតិវិធី និងសំណុំរឿង ។

៤.នៅដំណាក់កាលជំនុំជម្រះ សវនាការៈ

នៅគ្រប់សំណុំរឿងពីករណីបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបន្ទុកទទួលខុសត្រូវជាម្ចាស់បណ្តឹង និង/ឬ ម្ចាស់ករណីត្រូវមានវត្តមានថ្លែងហេតុ ធ្វើរបាយការណ៍ ការពារភស្តុតាង អង្គហេតុ អង្គច្បាប់នៃបណ្តឹងលើបទល្មើស ហើយបន្ថែមលើនេះ មន្ត្រីទទួលបន្ទុកមានសិទ្ធិសំណូមពរ និងទាមទារតាមផ្លូវច្បាប់ទាក់ទងនឹងរឿងក្តី ។

គ្រប់ដំណើរ និងកិច្ចនីតិវិធីរបស់តុលាការ ត្រូវតែមានសមាសភាពចូលរួមរបស់មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

**មាត្រា ៦២._**

នីតិវិធីកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ទម្រង់និងបែបបទនៃការធ្វើកំណត់ហេតុបទល្មើស ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

**មាត្រា ៦៣._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានប័ណ្ណសម្គាល់ខ្លួន និងឋានន្តរសក្តិក្នុងពេលចុះបំពេញបេសកកម្ម។

# ជំពូកទី ១១
# បទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦៤._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធដទៃទៀត ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលដែលបានផ្តើមគំនិត ឬសមគំនិត ត្រូវទទួលខុសត្រូវដូចចារី ដែលប្រព្រឹត្តផ្ទាល់ដែរ ។ ចំពោះការការកំណត់និយមន័យរបស់អ្នកផ្តើមគំនិត ឬអ្នកសមគំនិតត្រូវអនុលោមតាមក្រមព្រហ្មទណ្ឌ ។

**មាត្រា ៦៥._**

អំពើទាំងឡាយណាដែលមិនសហការ មិនអនុញ្ញាត ឬមានចេតនាគេចវេសក្នុងការឲ្យមន្ត្រីអធិការកិច្ច នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលធ្វើអធិការកិច្ច ឬចូលជួបជាមួយប្រធានក្រុមប្រឹក្សាភិបាល ឬអ្នករដ្ឋបាល ដើម្បីធ្វើការវាយតម្លៃលើការអនុវត្ត ។

**មាត្រា ៦៦._**

ការដែលប្រព្រឹត្តល្មើសនឹងល័ក្ខខ័ណ្ឌដូចមានកំណត់នៅក្នុង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន ។

**មាត្រា ៦៧._**

អំពើទាំងឡាយណាដែលប្រព្រឹត្តដោយមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ជាអាទិ៍ការបំពាន ការប្រកែក ការមានចេតនាគេចវេស ឬការមិនបំពេញតួនាទីរបស់ខ្លួនមានចែងក្នុងមាត្រា ៥៨ និង មាត្រា ៦១ នៃច្បាប់នេះ ។

**មាត្រា ៦៨._**

ត្រូវចាត់ទុកជាអំពើល្មើស រាល់សកម្មភាពគម្រោងស្នើសុំទាំងឡាយណា ដែលចាប់ផ្តើមសាងសង់ ឬដំណើរការគម្រោង ដោយមិនទាន់ទទួលបាននូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ ។

**មាត្រា ៦៩._**

អំពើទាំងឡាយណាដែលប្រព្រឹត្តិដោយម្ចាស់គម្រោង ប្រតិបត្តិករ ម្ចាស់ភាគហ៊ុន ដែលនាំឱ្យកើតមានកំហុសបច្ចេកទេស នៅក្នុងដំណាក់កាលនៃប្រតិបត្តិការគម្រោង។

**មាត្រា ៧០._**

អំពើក្លែងបន្លំទិន្នន័យ ឬលួចទិន្នន័យអ្នកដទៃ ដែលប្រព្រឹត្តិដោយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបានចុះបញ្ជីស្របច្បាប់ ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន ។

**មាត្រា ៧១._**

ការបំពាន ឬមិនគោរពតាមកិច្ចសន្យាការពារបរិស្ថាន ដែលបង្កឡើងដោយក្រុមហ៊ុន ឬម្ចាស់គម្រោង ។

**មាត្រា ៧២._**

ការមានចេតនាគេចវេស មិនព្រមសហការ ការបញ្ជា ឬការប្រើប្រាស់អំណាច ដែលបង្ខំឱ្យបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់ខ្លួនធ្វើការរារាំង ឬមិនអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលទៅក្នុងបរិវេណនៃទីតាំងគម្រោងដើម្បីធ្វើអធិការកិច្ច ។

**មាត្រា ៧៣._**

អំពើប្រកបវិជ្ជាជីវៈយកកម្រៃរបស់ក្រុមហ៊ុនទីប្រក្សា ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលពុំមានការទទួលស្គាល់ស្របច្បាប់ ដូចមានចែងក្នុងមាត្រា១៨នៃច្បាប់នេះ ។

**មាត្រា ៧៤._**

ការដែលមិនគោរពតាមតាមគោលការណ៍ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការរំលោភបំពានច្បាប់ ឬការប្រព្រឹត្តល្មើសនៅក្នុងការដ្ឋានសាងសង់ សំណង់ទូទៅ សំណង់ពាណិជ្ជកម្ម ការវិនិយោគ ទោះបីគម្រោងនោះមាន ឬគ្មាន លិខិតអនុញ្ញាតពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានបង្កឲ្យមាន មហន្តរាយធ្ងន់ធ្ងរដល់មនុស្សសត្វ ទ្រព្យសម្បត្តិបរិស្ថាន និងសង្គម ។

**មាត្រា ៧៥._**

រាល់អំពើទាំងឡាយណា ដែលបានផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមិនបានធ្វើការពិចារណា លើអនុសាសន៍របស់គណៈកម្មការជំនាញ-ត្រួតពិនិត្យ ឬដោយគ្មានឯកសារចាំបាច់គ្រប់គ្រាន់ ។

**មាត្រា ៧៦._**

រាល់អំពើទាំងឡាយដែលរំលោភលើសិទ្ធិនិងអំណាច ជាអាទិ៍ ការសម្រួល ការធ្វើអន្តរាគមន៍ ការបិទបាំង ការរារាំង ឬការសមគំនិតជាមួយនឹងចារី ដើម្បីប្រព្រឹត្តល្មើសគ្រប់រូបភាព ដោយមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឬពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត ។

# ជំពូកទី ១២
# ទោសប្បញ្ញត្តិ

**មាត្រា ៧៧._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងច្បាប់នេះ ត្រូវទទួលទោសជាអាទិ៍ ទោសរដ្ឋបាល ទោសពិន័យអន្តរការណ៍ និងទោសព្រហ្មទណ្ឌ ។

ទោសរដ្ឋបាលមានជាអាទិ៍ ការព្យួរការងារ ការដកហូតពីតួនាទី ឬមុខតំណែង និងបញ្ឈប់ពីក្របខណ្ឌការងារ ។

ទោសពិន័យអន្តរការណ៍មានជាអាទិ៍ ការព្រមាន ការជួសជុល ការស្ដារការខូចខាត និងការព្យួរលិខិតអនុញ្ញាត ការលុបចោលលិខិតអនុញ្ញាត ការលុបចោលកិច្ចសន្យា ការដកហូតអាជ្ញាប័ណ្ណ ការបង់ប្រាក់ពិន័យ ។

ក្នុងករណីដែលក្រុមហ៊ុន ឬម្ចាស់គម្រោងមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងបរិស្ថាន អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី/ខេត្ត អាចប្ដឹងទៅតុលាការ ។

ទោសព្រហ្មទណ្ឌមានជាអាទិ៍ ទោសពន្ធនាគារ ទោសពិន័យជាប្រាក់ ។

ការកំណត់ទោសទណ្ឌខាងលើនេះ មិនអាចឱ្យចារីរួចផុតពីការទទួលខុសត្រូវលើសំណងការខូចខាត និងសំណងជម្ងឺចិត្តបានឡើយ ។

**មាត្រា ៧៨._**

ពិន័យអន្តរការណលើបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចអនុវត្តទៅបាន លុះត្រាតែជនល្មើសទទួលស្គាល់កំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ។ ចំពោះការបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃទទួលបាននូវសេចក្ដីសម្រេចពិន័យ ។

បែបបទនិងសិទ្ធិសម្រេចនៃពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

ប្រាក់ដែលបានមកពីពិន័យអន្តរការណ៍ និងប្រាក់ដែលបានមកពីការលក់វត្ថុរឹបអូស ត្រូវបង់ចូលក្រសួងបរិស្ថាន ។

**មាត្រា ៧៩._**

ការកំណត់បរិមាណនៃទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវធ្វើការពិចារណាដូចតទៅ៖

- កម្រិតខូចខាតបរិស្ថានដែលបានបង្កឡើង
- ចំនួននៃការប្រព្រឹត្តបទល្មើស
- ចេតនានៃការប្រព្រឹត្តបទល្មើស
- ភាពមិនរាងចាលនៃបទល្មើស
- ទំហំនៃផលប្រយោជន៍សេដ្ឋកិច្ចរបស់គម្រោង។

**មាត្រា ៨០._**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថានបង្កឱ្យប៉ះពាល់ ឬខូចខាតដល់បរិស្ថាន ត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតអោយមានលក្ខខណ្ឌដូចដើមវិញ។ ក្នុងករណីមិនអាចស្តារ ឬជួសជុលអោយមានលក្ខណៈដូចដើមវិញបានទេ ត្រូវធ្វើការស្តារ ឬជួសជុលអោយមានលក្ខណៈសមរម្យ ដែលអាចទទួលយកបានដោយក្រសួងបរិស្ថាន។

**មាត្រា ៨១._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៦ នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលដល់ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីដែលអំពើនោះធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។ ប៉ុន្តែ ប្រសិនបើអំពើនោះប៉ះពាល់ធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០(ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

**មាត្រា ៨២._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តិល្មើសនឹងមាត្រា ៦៧ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

ប៉ុន្តែ ប្រសិនបើសកម្មភាព ឬគម្រោងដែលខុសច្បាប់នោះនៅតែបន្ត ហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតមនុស្ស ម្ចាស់គម្រោង ឬក្រុមហ៊ុនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីសកម្មភាព ឬគម្រោងដែលខុសច្បាប់នោះនៅតែបន្ត ហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្វ ទ្រព្យសម្បត្តិ ឬសង្គម ម្ចាស់គម្រោង ឬក្រុមហ៊ុន ត្រូវសងសមាមាត្រនឹងទំហំនៃការខូចខាត ។

វត្ថុតាងដែលបានរឹបអូសពីបទល្មើសត្រូវទុកជាសម្បត្តិរដ្ឋ ។

**មាត្រា ៨៣._**

មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ នៃច្បាប់នេះ ត្រូវទទួលការព្រមាន ព្យួរការងារជាបណ្តោះអាសន្ន ឬបញ្ឈប់ពីមុខតំណែងក្នុងករណីធ្ងន់ធ្ងរ ។

ការទទួលទោសរដ្ឋបាលខាងលើនេះ មិនរារាំងក្នុងការដាក់ទោសព្រហ្មទណ្ឌពីតុលាការឡើយ ។

**មាត្រា ៨៤._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៩ ត្រូវទទួលទោសដោយបង់ប្រាក់ពិន័យអន្តរការណ៍ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ឬជួសជុល ស្តារការខូចខាត ដែលបានបង្កឡើង ។

ក្នុងករណីដែលគម្រោង ការដ្ឋាន បានដំណើរ ហើយធ្វើឲ្យប៉ះពាល់ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គមជាអវិជ្ជមាន ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្ម ជាអាទិ៍ ការសងសំណងការខូចខាត ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា និងការដកហូតអាជ្ញាប័ណ្ណ ។

ការដាក់ទណ្ឌកម្មខាងលើនេះ មិនអាចឱ្យជនល្មើសរួចផុតការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើល្មើសនោះបំពានលើច្បាប់នេះ និងច្បាប់ពាក់ព័ន្ធ ។

**មាត្រា ៨៥._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧០ នៃច្បាប់នេះ ត្រូវទទួលទោសជាអាទិ៍ ការព្រមានជាលាយលក្ខណ៍អក្សរ និងធ្វើការកែតម្រូវ ។

វិធានការនៃការកែតម្រូវត្រូវកំណត់នៅក្នុងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨៦._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧១ នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីមិនរាងចាលត្រូវផ្អាកមិនអោយប្រកបវិជ្ជាជិវៈរយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ប៉ុន្តែប្រសិនបើ មានអំពើបន្លំ ក្លែងទិន្នន័យ ឬលួចទិន្នន័យធ្វើឱ្យមានការប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ ត្រូវលុបឈ្មោះពីបញ្ជីអ្នកជំនាញធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមិនឲ្យប្រកបវិជ្ជាជីវៈជារៀងរហូត ។

**មាត្រា ៨៧._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

ប៉ុន្តែ ប្រសិនបើសកម្មភាព ឬគម្រោងដែលខុសច្បាប់នោះនៅតែបន្ត ហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតមនុស្ស ម្ចាស់គម្រោង ឬក្រុមហ៊ុនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥

(ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីសកម្មភាព ឬគម្រោងដែលខុសច្បាប់នោះនៅតែបន្ត ហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្វ ទ្រព្យសម្បត្តិ ឬសង្គម ម្ចាស់គម្រោង ឬក្រុមហ៊ុន ត្រូវសងសមាមាត្រនឹងទំហំនៃការខូចខាត ។

**មាត្រា ៨៨._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

**មាត្រា ៨៩._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៤ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរកាលជាប្រាក់ពី ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

**មាត្រា ៩០._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ប៉ុន្តែ ក្នុងករណីដែលអំពើល្មើសនោះ បង្កឱ្យមានការបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ដល់រូបរាងកាយ និងស្មារតី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីសកម្មភាព ឬគម្រោងដែលខុសច្បាប់នោះនៅតែបន្ត ហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្វ ទ្រព្យសម្បត្តិ ឬសង្គម ម្ចាស់គម្រោង ឬក្រុមហ៊ុន ត្រូវសងសំណងសមាមាត្រនឹងទំហំនៃការខូចខាត ។

**មាត្រា ៩១._**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ។

មិនតែប៉ុណ្ណោះចំពោះអំពើល្មើសនឹងមាត្រា ៧៧ ដដែលនេះ ចារីត្រូវសងសំណងការខូចខាតដែលមានចំនួនសមាមាត្រទៅនឹងទំហំនៃការខូចខាតដែលបានបង្កឡើង ។

**មាត្រា ៩២._**

ជនដែលមានសិទ្ធិសម្រេចនៃក្រសួងបរិស្ថានដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៦ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ។

## ជំពូកទី ១៣
## ការអនុវត្តន៍សេចក្តីសម្រេចតុលាការ

**មាត្រា ៩៣._**

មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន មានភារកិច្ចអនុវត្តនូវសេចក្តីសម្រេចរបស់តុលាការក្រោមការបង្គាប់បញ្ជារបស់តុលាការ ។

**មាត្រា ៩៤._**

រាល់ទម្រង់នៃសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹង បទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថានតម្រូវចម្លងជូន ក្រសួងបរិស្ថាន ។

**មាត្រា ៩៥._**

បន្ទាប់ពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែង តាមនីតិវិធីរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ១៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៩៦._**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ ។

**មាត្រា ៩៧._**

រាល់គម្រោងអភិវឌ្ឍន៍ សកម្មភាពអាជីវកម្ម និងសកម្មភាពវិនិយោគនានារបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវគោរពបទប្បញ្ញត្តិនៃច្បាប់នេះឲ្យ មានប្រសិទ្ធភាព។ រាល់បែបបទនីតិវិធីអនុវត្ត និងបទដ្ឋានបច្ចេកទេស ដែលមិនមានចែងក្នុងច្បាប់នេះ ត្រូវកំណត់នៅក្នុងអនុ-

ក្រឹត្យ ប្រកាស សារាចរ និងសេចក្តីណែនាំនានា តាមសំណើរបស់រាជរដ្ឋាភិបាល ឬក្រសួងបរិស្ថាន ។

# ជំពូកទី ១៥
# អវសានប្បញ្ញត្តិ

**មាត្រា ៩៨.**_

១. បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

២. ការចូលជាធរមានក្នុងការអនុវត្តច្បាប់នេះ ត្រូវអនុវត្តតាមប្រកាសផ្សព្វផ្សាយ ជាផ្លូវការ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ........ ខែ ........ ឆ្នាំ...........
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ...........នីតិកាលទី៥ ។

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............ ឆ្នាំ...............

**ប្រធានរដ្ឋសភា**

**ឧបសម្ព័ន្ធទី ១៖**

# វាក្យស័ព្ទ

**ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**
ច្បាប់នេះចែង និងបញ្ញត្តិ អំពីការគ្រប់គ្រងលើកិច្ចដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា។ រាល់សកម្មភាព ចលនា ការប្រព្រឹត្តទាំងអស់របស់បុគ្គល គ្រួសារ ម្ចាស់ទីតាំង ម្ចាស់កម្មសិទ្ធិ ទោះជារូបវន្តបុគ្គល ជានីតិបុគ្គលឯកជន ឬជានីតិបុគ្គលសាធារណៈ ជាអង្គភាព ជាក្រសួង ជាស្ថាប័នរដ្ឋ ឬជារដ្ឋនិងរដ្ឋក្តី ដែលបានធ្វើសកម្មភាពគ្រប់យ៉ាងនិងដែលបានផ្លាស់ប្តូរស្ថានភាពដើមនៃបរិស្ថាន សេដ្ឋកិច្ច សង្គម វប្បធម៌ ត្រូវគោរពអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចំពោះសកម្មភាពដែលមានស្រាប់ ដែលកំពុងដំណើរការ ឬដែលរៀបចំចាប់ផ្តើម ។

**បណ្តុំនៃហេតុប៉ះពាល់** : បណ្តុំនៃហេតុប៉ះពាល់ គឺ ជាហេតុប៉ះពាល់ទាំងឡាយណា ដែលកើតមក ពីហេតុប៉ះពាល់ចំនួនបន្ថែមរបស់គម្រោង ដែលបន្ថែមលើសកម្មភាពពី អតីតកាល បច្ចុប្បន្ន និង អនាគត ។

**ការឯកភាពលើគម្រោងអភិវឌ្ឍន៍** : ជាការអនុម័ត ឬ ការអនុញ្ញាត ដែលផ្តល់អោយដោយ រដ្ឋាភិបាលកម្ពុជាសម្រាប់គម្រោង ឬ ដោយស្ថាប័នផ្សេងទៀត រួមទាំង កិច្ចសន្យាសម្បទាន ។

**អ្នកទទួលហេតុប៉ះពាល់ផ្ទាល់**: ជាអ្នកទទួលហេតុប៉ះពាល់ដែលមាន សិទ្ធិតទល់ ហានិភ័យ និង ការទទួលខុសត្រូវលើបញ្ហា ។ អ្នកទាំងនោះ អាចជាអ្នកដែលនៅក្នុងតំបន់ដែលគម្រោងតាំងនៅ (ឧទាហរណ៍ សហគមន៍ដែលរងហេតុប៉ះពាល់ពីគម្រោង ) ឬ នៅក្រៅតំបន់គម្រោងតាំងនៅ (និយតករ រដ្ឋាភិបាល តំណាងស្ថាប័នហិរញ្ញវត្ថុ ឬ ដៃគូវិនិយោគទុនផ្សេងៗ។)

**ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច(Ethnic Minorities Development Plan):**ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច មានអត្ថន័យដែលត្រូវបានផ្តល់ឱ្យវា ដោយអនុក្រិតស្តីពី សំណង និងការផ្លាស់ទីលំនៅរបស់ប្រជាជន ដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍នានា [ដែលនឹងត្រូវពង្រាងសម្រាប់ការពិចារណា] ។

**ការវាយតម្លៃបរិស្ថាន**: ជាដំណើរការ ដោយយោងតាម ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ច្បាប់ពាក់ព័ន្ធ ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ**: គឺជាការវាយតម្លៃយ៉ាងលំអិត ពីហេតុប៉ះពាល់បរិស្ថាន និង សង្គម ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺ ជាដំណើរការសិក្សា និង ការប្រមើមើលពីហេតុប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន លើបរិស្ថាន និង សង្គម ដើម្បីកំនត់ពីវិធានការ

ការពារ និង កាត់បន្ថយហេតុប៉ះពាល់លើបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និង សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

**វិញ្ញាប័នបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន**: គឺជាវិញ្ញាបនបត្រ ដែលចេញដោយ ក្រសួងបរិស្ថាន ដោយយោងតាមការវាយតម្លៃបរិស្ថានរបស់គម្រោង ដែលមានចែងលំអិតអំពី ផែនការគ្រប់គ្រងបរិស្ថាន និង លក្ខខណ្ឌដែលចេញដោយក្រសួងបរិស្ថាន ។

**ផែនការគ្រប់គ្រងបរិស្ថាន**: សំដៅលើផែនការ ដែលមានចែងនៅក្នុង របាយការណ៍វាយ តម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ដែលបានកំនត់ពីវិធានការការពារ និង កាត់បន្ថយ ហេតុប៉ះពាល់ ការទទួលខុសត្រូវ និង កាលវិភាគសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ផែនការតាមដាន និង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីគម្រោង ដោយរួមបញ្ចូលទាំង ផែនការហិរញ្ញវត្ថុសម្រាប់ សកម្មភាពបរិស្ថានក្នុងតំណាក់កាលសាងសង់ ដំណើរការ និង ការបញ្ចប់គម្រោង ។

**ប្រព័ន្ធគ្រប់គ្រងបរិស្ថាន** (**Environmental Management System**) មានអត្ថន័យដែលត្រូវបានផ្តល់ឱ្យវា ដោយស្តង់ដារនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001 នៃឆ្នាំ ២០០៤ ។

**របាយការណ៍អង្កេតតាមដានបរិស្ថាន**: ជារបាយការណ៍ស្តីពីការតាមដាន និង វាយតម្លៃបរិស្ថានរបស់គម្រោងអភិវឌ្ឍន៍ ដូចដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលដាក់ជូនក្រសួងបរិស្ថាន ។ កម្មវិធីតាមដាន ត្រូវអនុវត្តតាមដំណើរការ និង ការកំនត់ពី គុណភាពបរិស្ថានដូចមានចែងក្នុង ផែនការគ្រប់គ្រងបរិស្ថាន ដែលបានអនុម័តជាផ្លូវការ ។

**គម្រោងដែលមានស្រាប់**: គម្រោងដែលមានស្រាប់ គឺ ជាគម្រោងទាំងឡាយណា ដែលកំពុងសាងសង់ ដំណើរការ ឬ នៅដំណាក់កាលបញ្ចប់នៃក្នុងវដ្តគម្រោង ដែលកំពុងអនុវត្តមុន ពេលចូលជាធរមានរបស់ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**អ្នកត្រួតពិនិត្យឯករាជ្យ**: ជាអ្នកត្រួតពិនិត្យជំនាញ ដែលមិនបានជួលមកដោយគម្រោង និង ពុំបានទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីគម្រោង ។

**ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ**: មានន័យថា កិច្ចដំណើរការចូលរួមសាធារណៈត្រូវតម្រូវឱ្យម្ចាស់គម្រោងផ្តល់ព័ត៌មានដល់សហគន៍ អំពីវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន មុនពេលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម និងពេញលេញ ត្រូវបានបញ្ជូនទៅក្រសួងបរិស្ថាន។ ម្ចាស់គម្រោងត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សហគមន៍ដែលរងផលប៉ះពាល់ ក្នុងការពិចារណាលើវិធានការកាត់បន្ថយផលប៉ះពាល់នេះ ។ សហគមន៍ដែលរងផលប៉ះពាល់ត្រូវឯកភាពលើវិធានការណ៍កាត់បន្ថយផលប៉ះពាល់ ដោយពុំមានទទួលរងការដាក់សម្ពាធ ឬការបង្ខិតបង្ខំពីរូបវន្តបុគ្គល ឬនីតិបុគ្គលណាឡើយ ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង:** គឺជាការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន និង សង្គម ដំបូង ដើម្បីប្រមើមើលផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និង សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ដោយរំពឹងថានឹងមានហេតុប៉ះពាល់តិចបំផុត ដែលអាចមានវិធានការ កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ។

**ផែនការគ្រប់គ្រង:** ផែនការគ្រប់គ្រង គឺ ជាឧបករណ៍សម្រាប់ប្រើជាឯកសារគោលក្នុងការគ្រប់គ្រង ជាពិសេស បញ្ហាគម្រោង និង ជាយន្តការសម្រាប់ដោះស្រាយទៅនឹងសំនួរ ហេតុអ្វី ជាអ្វី យ៉ាងម៉េច នរណា ប៉ុន្មាន និង ពេលណា សម្រាប់បញ្ហាទាំងនោះ ។

**ប្រព័ន្ធគ្រប់គ្រង** (**Management System**): ក្របខណ្ឌនៃដំណើរការ និងនីតិវិធីនានា ដែលត្រូវបានប្រើប្រាស់ក្នុងការធានាឱ្យបានថា អង្គការណា១អាចបំពេញកិច្ចការទាំងអស់ ដែលចាំបាច់តម្រូវឱ្យធ្វើ ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងឡាយរបស់ខ្លួន។

**ការកាត់បន្ថយ (Offset):** ការអភិរក្សដែលអាចវាស់វែងបាន កើតពីសកម្មភាពដើម្បីបង្កើតអោយមាន សំណងជំងឺចិត្តលើហេតុប៉ះពាល់លើជីវចំរុះ ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ និង យន្តការសមរម្យ សម្រាប់ជៀសវាង កាត់បន្ថយ និង ការស្តារឡើងវិញ ។ ជាទូទៅ វាមិនស្ថិតនៅក្នុងទីតាំងរបស់គម្រោងទេ ។

**អ្នកស្នើសុំគម្រោង:** អ្នកស្នើគម្រោង គឺជាម្ចាស់គម្រោង ឬ អ្នកអភិវឌ្ឍន៍គម្រោង ដែលសំដៅលើរូបវន្ត បុគ្គលទាំងឡាយ នីតិបុគ្គល ឬ ស្ថាប័ន ដែលបានទទួលការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវ កសាង និង អនុវត្តគម្រោង ។ អ្នកស្នើគម្រោង អាចមកពីស្ថាប័នឯកជន ស្ថាប័នរដ្ឋ ឬ ស្ថាប័នទទួលបន្ទុក អភិវឌ្ឍន៍ ។

**ការចូលរួមជាសាធារណ:** ការចូលរួមជាសាធារណៈ មានន័យថា ជាការពិគ្រោះយោបល់ និង ការចូលរួមពិភាក្សាក្នុងដំណើរការ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការផ្លាស់ប្តូរគំនិត និង មតិយោបល់ ការទទួលយកព័តមានពីគ្រប់ភាគីដែលនឹងទទួលរងហេតុប៉ះពាល់ផ្ទាល់ និង ប្រយោល ពីគម្រោងអភិវឌ្ឍន៍ និង ដំណោះស្រាយបញ្ហា ដែលរាប់ចាប់តាំងពីកំឡុងពេលតាក់តែងផែនការ ការអនុវត្ត និង ការជួសជុលផ្នែកបរិស្ថាន និង ការស្តារឡើងវិញ មុនពេលបញ្ចប់គម្រោង ។

**ការស្តារជាថ្មី** (**Refurbishment**): ស្ថានភាពនៃការស្តារទៅកាន់ស្ថានភាពល្អរបស់វាកាលពីមុន។

**គម្រោងផែនការផ្លាស់ទីលំនៅថ្មី (Resettlement Action Plan):** ជាឯកសារ ឬ បណ្តុំឯកសារ ដែលធ្វើឡើងជាពិសេស ដើម្បីកំនត់សកម្មភាព ដែលនឹងយកមកប្រើដើម្បីជាដំណោះស្រាយបញ្ហា (ផែនការទាំងនេះ នឹង កំនត់ដោយសេចក្តីណែនាំស្តីពី សំណងជំងឺ ចិត្ត និង ដំណោះស្រាយ

សម្រាប់ប្រជាជនដែលរង ហេតុប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍)។ ផែនការនេះ ត្រូវបញ្ចូល អត្តសញ្ញាណរបស់អ្នកដែល ត្រូវបានទទួលការដោះស្រាយ ការសិក្សាពីសង្គម-សេដ្ឋកិច្ច សម្រាប់អ្នកដែលទទួលការដោះស្រាយ វិធានការដែលនឹងយកមកអនុវត្ត ដែលជាផ្នែកមួយនៃ ដំណើរការដោះស្រាយ ដោយរាប់ទាំងជំនួយ នានា ក្នុងការដោះស្រាយបញ្ហា និង ការគាំទ្រផ្នែក ជីវភាព ព្រមទាំងយន្តការផ្នែកច្បាប់ និង សំណងជំងឺចិត្ត តួនាទី និង ការទទួលខុសត្រូវរបស់ ស្ថាប័ន ការគ្រប់គ្រងថវិកា និង ហរិញ្ញវត្ថុ ពេលវេលា កម្មវត្ថុ និង ក្រុមគោលដៅ យន្តការកែប្រែ ទុក្ខព្រួយ ការតាមដានរបាយការណ៍ និង ការពិនិត្យ និង ការយល់ដឹងពីការពិគ្រោះយោបល់ ការចូលរួម និង ការផ្លាស់ប្តូរព័ត៌មាន ។

**ការជ្រើសរើសគ្រោង:** ការជ្រើសរើសគម្រោង មានន័យថា ជាការកំនត់ប្រភេទគម្រោងស្នើសុំ ដើម្បីពិនិត្យមើលថាតើ គម្រោងនោះចាំបាច់អោយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**ការវាយតម្លៃហេតុប៉ះពាល់សង្គម:** គឺជាដំណើរការនៃការសិក្សា និង ប្រមើមើលពី ហេតុប៉ះពាល់ វិជ្ជមាន និង អវិជ្ជមាន លើផ្នែកសង្គមសេដ្ឋកិច្ចនៃសង្គមពីគម្រោង និង សកម្មភាព អភិវឌ្ឍន៍ ដែលកំនត់ពីវិធានការសមរម្យដើម្បីទប់ស្កាត់ កាត់បន្ថយ និង ផ្តល់ជំងឺចិត្ត ដល់បុគ្គលដែល ទទួលរងការប៉ះពាល់ពីគម្រោង ដែលអាចជាហេតុប៉ះពាល់លើជីវិត ជីវភាព សុខុមាលភាព និង សុខភាព ។

**ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ:** ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សំដៅលើលំដាប់ ទ្រឹស្តីនៃការវិភាគ និង ការចូលរួម ដែលមានគោលបំណង ដើម្បីរួមបញ្ចូលការពិនិត្យពិច័យ ផ្នែកបរិស្ថាន ទៅក្នុងគោលនយោបាយ ផែនការ និង កម្មវិធីផ្សេងៗ និង ការវាយតម្លៃ ការពិនិត្យ ពិច័យ ទំនាក់ទំនងរវាង សេដ្ឋកិច្ច និង សង្គម ។

**កិច្ចព្រមព្រៀងឆ្លងដែន:** ជាកិច្ចព្រមព្រៀង ដែលបង្កើតឡើងដោយរដ្ឋត្រីភាគី ស្តីពី របៀបនៃការ ចែករំលែកធនធាន ដែលនឹងប្រើប្រាស់ដោយភាគីដែលពាក់ព័ន្ធ ហើយនឹងដំណើរការ ដែលត្រូវ ធ្វើប្រតិបត្តិតាម ដើម្បីរក្សាខ្លឹមសារនៃការព្រមព្រៀងនេះ ។